សួស្តីអ្នកទាំងអស់គ្នា បាទ ជួបគ្នាម្តងទៀតហើយក្នុងថ្ងៃនេះ ហើយនៅក្នុងថ្ងៃនេះ
យើងនឹងមានប្រធានបទមួយដើម្បីលើកយកមកនិយាយ ដែលប្រធានបទរបស់យើងនៅក្នុងថ្ងៃនេះ
គឺយើងនឹងនិយាយអំពី ការដកប្រាក់នៅម៉ាស៊ីន នៅក្នុងម៉ាស៊ីនដកប្រាក់។ បាទ
អញ្ចឹងយើងនឹងនិយាយអំពីការដកប្រាក់។ អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នាតែម្តង។

នៅក្នុងរូបភាពទី ១ បាទ នៅក្នុងរូបភាពទី ១ យើងឃើញថា មានស្ត្រីម្នាក់ ឬក៏នារីម្នាក់ បាទ
គាត់មានអាយុប្រហែលជាម្ភៃប្រាំឆ្នាំ អញ្ចឹងនារីនោះ គាត់មានសក់វែងពណ៌ខ្មៅ
គាត់ពាក់អាវពណ៌ទឹកសមុទ្រដៃវែង បាទ ហើយគាត់ស្លៀកសំពត់ពណ៌ស ហើយនៅលើឆ្វេង
ខាងឆ្វេងដៃរបស់គាត់ គាត់បាន ស្មារបស់គាត់ គាត់បានស្ពាយកាបូបធំមួយ
អញ្ចឹងគាត់ស្ពាយកាបូបធំពណ៌សនៅលើស្មាខាងស្តាំរបស់គាត់ បាទ នៅលើស្មាខាងស្តាំ
ហើយដៃទាំងពីររបស់គាត់ គាត់បានចាប់កូនកាបូបមួយ អញ្ចឹងកូនកាបូបនោះ គឺជាកូនកាបូបលុយ
បាទ ដៃទាំងពីររបស់គាត់កំពុងតែកាន់កាបូបលុយពណ៌ទឹកក្រូច
ហើយគាត់ពិនិត្យមើលទៅក្នុងកាបូបលុយនោះ អញ្ចឹងគាត់ពិនិត្យមើលហើយ គាត់បានដឹងថា
កាបូបរបស់គាត់គឺមិនមានលុយនោះទេ យើងឃើញរូបភាពលុយដែលមានដុះស្លាបកំពុងតែហោះ
អញ្ចឹងនៅក្នុងរូបភាពនេះ បានន័យថាលុយរបស់គាត់គឺហោះចេញពីកាបូបអស់ហើយ
បានន័យថាគាត់ចំណាយលុយនៅក្នុងកាបូបលុយរបស់គាត់អស់ទាំងអស់តែម្តង
ទើបគាត់គិតអំពីលុយដែលមានស្លាបហោះចេញ អញ្ចឹងនារីម្នាក់នោះ
បានពិនិត្យទៅលើកាបូបលុយរបស់គាត់ ហើយគាត់ដឹងថា
គាត់បានចំណាយលុយនៅក្នុងកាបូបអស់ហើយ ដូច្នេះគាត់ត្រូវការលុយបន្ថែមទៀត។

ចូលមកដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ
គាត់បានពិនិត្យកាបូបលុយរបស់គាត់
ហើយគាត់អត់មានឃើញលុយនៅក្នុងកាបូបលុយរបស់គាត់នោះទេ អញ្ចឹងនារីម្នាក់នោះ
គាត់ក៏បានដើរមកកាន់ធនាគារមួយ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា
គាត់បានស្ពាយកាបូបធំរបស់គាត់នៅស្មាខាងស្តាំ បាទ ហើយដៃម្ខាងរបស់គាត់ខ្ទប់កាបូប
ឬក៏កាន់កាបូប ដើម្បីកុំឲ្យកាបូបយោល អញ្ចឹងនៅពេលដែលយើងដើរ យើងត្រូវកាន់កាបូប
ឬក៏ស្ពាយកាបូប កាបូបស្ពាយរបស់យើងហ្នឹង យើងត្រូវកាន់ ព្រោះថានៅពេលដែលយើងមិនកាន់
វានឹងយោលយោក ឬក៏យោលចុះឡើងៗ ដែលធ្វើឲ្យយើងពិបាកដើរ អញ្ចឹងនៅក្នុងរូបភាពនេះ
នារីម្នាក់នោះ គាត់ដើរបណ្តើរ កាន់កាបូបទប់ឲ្យនឹងបណ្តើរ ដើម្បីងាយស្រួលក្នុងការដើរ។
គាត់បានដើរមកដល់ធនាគារមួយ ដែលយើងឃើញថានៅខាងលើមាត់ទ្វារ
គឺគេមានដាក់សញ្ញាធនាគារ ហើយធនាគារនោះ គឺមានទ្វារចូលចំនួនពីរ បាទ ទ្វារចូលចំនួនពីរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែទ្វារធនាគារ ជាទូទៅគឺបិទ។ ដូច្នេះនៅពេលដែលអតិថិជនចូល អតិថិជនត្រូវបើកទ្វារដើម្បីចូល ព្រោះធនាគារបិទទ្វារ ដើម្បីរក្សាសុវត្ថិភាព ជាទូទៅទ្វារធនាគារ គឺជាទ្វារកញ្ចក់ ដែលអាចឲ្យយើងមើលឃើញខាងក្នុងបាន ដូច្នេះទោះជាបិទក៏ដោយ ក៏យើងអាចដឹងថា មានបុគ្គលិកនៅបម្រើការនៅក្នុងធនាគារឬក៏អត់ដែរ។

ចូលដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា នារីម្នាក់នោះ គាត់បានដើរមកដល់ធនាគារ ក៏ប៉ុន្តែគាត់មិនចូលទៅក្នុងធនាគារនោះទេ បាទ គាត់អត់ចូលទៅក្នុងធនាគារទេ គឺគាត់ដើរមករកតម្រង់ជួរវិញ។ អញ្ចឹងគាត់តម្រង់ជួរនៅក្នុងមនុស្សជាច្រើន។ នៅក្នុងរូបភាពទី ៣ នេះ យើងឃើញមនុស្សជាច្រើននាក់ ដែលឈរតម្រង់ជួរគ្នា បាទ អញ្ចឹងយើងឃើញមនុស្សជាច្រើនឈរតម្រង់ជួរគ្នា ដែលនៅខាងមុខគេបង្អស់ បាទ នៅខាងមុខគេបង្អស់ គឺនៅខាងស្តាំដៃបង្អស់ គឺមានបុរសម្នាក់ គាត់ពាក់អាវពណ៌ស ស្លៀកខោពណ៌ស ហើយពាក់ស្បែកជើងពណ៌សដែរ។ បន្ទាប់ពីបុរសនោះ យើងឃើញមានកុមារីម្នាក់ បាទ ឬក៏ក្មេងស្រី បាទ យើងអាចហៅបានពីរ កុមារីក៏បាន ក្មេងស្រីក៏បាន។ កុមារីនោះ គាត់ពាក់អាវពណ៌ស ស្លៀកខោពណ៌ខ្មៅ ហើយចងសក់ទីទុយ បាទ កុមារីនោះ គាត់ឈរនៅក្បែរឪពុករបស់គាត់ បាទ ឪពុករបស់គាត់ ដែលមានពាក់អាវពណ៌លឿង ដៃខ្លី ស្លៀកខោជើងវែងពណ៌ស បាទ កុមារីនិងឪពុកនោះ គាត់កំពុងតែឈរតម្រង់ជួរ។ ហើយទាំងពីរអ្នក ឪពុកកូន គឺឈរនៅចំកណ្តាលតែម្តង បាទ បានន័យថា គាត់នៅឈរចំកណ្តាលនៃជួរ គឺខាងមុខគាត់គឺមានបុរសម្នាក់ នៅខាងក្រោយគាត់មានបុរសម្នាក់ទៀត។ ហើយបុរសម្នាក់ទៀតដែលឈរនៅខាងក្រោយ បុរសដែលជាឪពុកនោះ គឺពាក់អាវពណ៌ស្វាយ ដៃខ្លី ស្លៀកខោជើងវែងពណ៌ស ហើយគាត់មានសក់ខ្លី អញ្ចឹងគាត់ពាក់អាវដៃវែង ដៃខ្លីពណ៌ស្វាយ។ ដៃស្តាំរបស់បុរសនោះ គឺគាត់ច្រត់ទៅក្នុង[...] ហោប៉ៅរបស់គាត់ អញ្ចឹងគាត់បានឈរច្រត់ហោប៉ៅ ឬក៏ជ្រែងហោប៉ៅ ដោយដាក់ដៃស្តាំចូលទៅក្នុងហោប៉ៅខោ អញ្ចឹងខោរបស់គាត់គឺមានហោប៉ៅមួយ បាទ អញ្ចឹងគាត់ដាក់ដៃស្តាំរបស់គាត់ចូលក្នុងហោប៉ៅ។ ពួកគេទាំងបីនាក់កំពុងតែឈរតម្រង់ជួរគ្នា។ បាទ ពួកគេទាំងបីនាក់កំពុងតែឈរតម្រង់ជួរគ្នា។ ហើយពេលនោះ នារីដែលមានវ័យអាយុប្រហែលជាម្ភៃប្រាំឆ្នាំ ដែលស្ពាយកាបូបធំនោះ គាត់បានដើរមកដល់ការតម្រង់ជួរនោះ គឺគាត់ឃើញមនុស្សជាច្រើនកំពុងតែឈរតម្រង់ជួរគ្នា។

នៅក្នុងរូបភាពទី ៤ ចូលមកដល់រូបភាពទី ៤ យើងឃើញថា ការតម្រង់ជួរគ្នានោះ គឺមនុស្សទាំងអស់រង់ចាំតម្រង់ជួរគ្នា នៅខាងមុខទូអេធីអឹម ឬក៏ម៉ាស៊ីនដកប្រាក់។ អញ្ចឹងដើម្បីធ្វើការដកប្រាក់ យើងពុំចាំបាច់ចូលទៅក្នុងធនាគារទេ ព្រោះថាគ្រប់ធនាគារទាំងអស់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

តែងតែមានម៉ាស៊ីនដកប្រាក់ ឬក៏យើងអាចហៅថា អេធីអឹម។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា គ្រប់ធនាគារ គឺសុទ្ធតែមានម៉ាស៊ីនដកប្រាក់ទាំងអស់ ហើយប្រជាជនកម្ពុជា ភាគច្រើន គាត់ពុំសូវហៅម៉ាស៊ីនដកប្រាក់នោះទេ ព្រោះវាវែង បាទ ឈ្មោះវាវែងពេក អញ្ចឹងគេហៅអក្សរកាត់ដូចគ្នាគឺ អេធីអឹម ឬក៏ម៉ាស៊ីនអេធីអឹម។ អញ្ចឹងនៅក្នុងរូបភាពនេះ មនុស្សទាំងអស់កំពុងតែឈរតម្រង់ជួរនៅខាងមុខម៉ាស៊ីនអេធីអឹម ព្រោះថានៅពេលដែលមានមនុស្សច្រើន ដើម្បីរក្សាសណ្តាប់ធ្នាប់ យើងត្រូវឈរតម្រង់ជួរគ្នា អ្នកណាមកមុន គឺឈរខាងមុខ ហើយអ្នកណាមកក្រោយ គឺឈរខាងក្រោយ បាទ នៅក្នុងរូបភាពនេះ យើងឃើញថា បុរសដែលពាក់អាវស ខោជើង[ស] ខោជើងវែងពណ៌ស គាត់ឈរខាងមុខគេ នៅជាប់ម៉ាស៊ីនអេធីអឹមតែម្តង គឺគាត់កំពុងតែដកប្រាក់ អញ្ចឹង បានន័យថា បុរសនោះ គាត់មកមុនគេ អញ្ចឹងគាត់ត្រូវឈរខាងមុខ បន្ទាប់មកបុរសពាក់អាវលឿង និងកូនស្រី គឺគាត់មកទី ២ គឺគាត់ឈរបន្ទាប់ បុរសពាក់អាវស្វាយ គាត់មកបន្ទាប់ គឺគាត់ឈរខាងក្រោយទី ៣ រីឯនារីម្នាក់នោះ គាត់ឈរខាងក្រោយគេ ព្រោះថាគាត់មកខាងក្រោយគេ ទោះបីជាមានអាការៈប្រញាប់ប្រញាល់ក៏ដោយ ក៏នារីម្នាក់នោះមិនប្រជែង ឬក៏ប្រជ្រៀតទៅខាងមុខដែរ ព្រោះថាគាត់មកខាងក្រោយ គឺត្រូវឈរខាងក្រោយ ដូច្នេះវាអាចរក្សាសណ្តាប់ធ្នាប់ និងបានន័យថា យើងបង្ហាញអំពីសុជីវធម៌ និងសីលធម៌របស់យើងផងដែរ ព្រោះថាជាទូទៅ ការមកមុន គឺត្រូវឈរខាងមុខ ការមកក្រោយ គឺត្រូវឈរខាងក្រោយ វាគឺជាសុជីវធម៌ និងសណ្តាប់ធ្នាប់មួយល្អផងដែរ។

នៅក្នុងរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា ម៉ាស៊ីនអេធីអឹមនោះ បានបើកបម្រើប្រជាជនទាំងអស់ ហើយមនុស្សដែលនៅឈរតម្រង់ជួរគ្នានោះ បានចូលម្នាក់ម្តងៗ ទៅតាមវេនរបស់ពួកគេ តាមការមកមុនមកក្រោយ អញ្ចឹងអ្នកមកមុន គាត់ដកមុន អ្នកមកក្រោយ គាត់ដកក្រោយ។ អញ្ចឹងនារីម្នាក់នោះ គាត់ឈរចាំរហូតទាល់តែដល់បុរសម្នាក់ដែលពាក់អាវស្វាយ គាត់ចូលប្រើប្រាស់ម៉ាស៊ីនអេធីអឹមរួចរាល់។ អញ្ចឹងនៅក្នុងរូបភាពទី ៥ យើងឃើញថា បុរសដែលពាក់អាវស្វាយនោះ គាត់បានប្រើប្រាស់ម៉ាស៊ីនអេធីអឹមរួចរាល់ហើយ ហើយគាត់បានជ្រែងហោប៉ៅ ដោយយកដៃឆ្វេងរបស់គាត់ច្រត់ហោប៉ៅ ហើយដើរចេញពីម៉ាស៊ីនអេធីអឹមនោះ។ អញ្ចឹង បានន័យថា គាត់បានប្រើប្រាស់ ឬក៏គាត់បានដកលុយចេញពីម៉ាស៊ីនអេធីអឹមនោះ សម្រាប់តម្រូវការគាត់រួចរាល់ហើយ។ បន្ទាប់ពីបុរសម្នាក់ដែលពាក់អាវស្វាយនោះ គាត់ដើរចេញពីម៉ាស៊ីនអេធីអឹម នារីដែលឈរពីក្រោយមនុស្សប្រុសពាក់អាវស្វាយនោះ គាត់ក៏ចូលប្រើប្រាស់ម៉ាស៊ីនអេធីអឹមម្តង។ អញ្ចឹង បានន័យថា ដល់វេនគាត់ប្រើប្រាស់ម្តងហើយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះគាត់បានចូលទៅប្រើប្រាស់ម៉ាស៊ីនអេធីអឹម ដោយអាការៈប្រញាប់ប្រញាល់ ព្រោះនារីម្នាក់នោះ គាត់ត្រូវការលុយយ៉ាងខ្លាំង ដោយសារតែកាបូបលុយរបស់គាត់ពុំមានលុយនោះទេ។

អញ្ចឹងចូលដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ នារីម្នាក់នោះ
គាត់ក៏បានឈរនៅខាងមុខម៉ាស៊ីនអេធីអឹម ឬក៏ម៉ាស៊ីនដកប្រាក់ បាទ ហើយដៃឆ្វេងរបស់គាត់
គាត់កាន់កាតអេធីអឹម បាទ អញ្ចឹងក្នុងការប្រើប្រាស់ម៉ាស៊ីនអេធីអឹម យើងត្រូវមានកាតធនាគារមួយ
ឬក៏គេហៅថាកាតអេធីអឹម យើងត្រូវបញ្ចូលកាតអេធីអឹមនោះទៅក្នុងម៉ាស៊ីនអេធីអឹម
ឬក៏ម៉ាស៊ីនដកប្រាក់ អញ្ចឹងរូបភាពនេះ យើងឃើញថា ដៃឆ្វេង ដៃស្តាំរបស់នារីនេះ បាទ នារីនេះ
គាត់ប្រើប្រាស់ដៃស្តាំរបស់គាត់ ដើម្បីកាន់កាតអេធីអឹមដាក់ចូលទៅក្នុងម៉ាស៊ីន។
អញ្ចឹងគាត់ដាក់ចូលនូវកាតនៅក្នុងម៉ាស៊ីន ដើម្បីឲ្យម៉ាស៊ីនពិនិត្យទៅលើអាខោនធនាគារ
ឬក៏ពិនិត្យទៅលើគណនីធនាគាររបស់គាត់ថាត្រឹមត្រូវឬទេ។ អញ្ចឹង ជាទូទៅ
យើងប្រើប្រាស់ម៉ាស៊ីនអេធីអឹម យើងត្រូវប្រើកាត ដើម្បីដាក់ចូលក្នុងម៉ាស៊ីន
ដើម្បីឲ្យម៉ាស៊ីនត្រួតពិនិត្យថា តើគណនីរបស់យើងត្រឹមត្រូវដែរឬទេ។

ចូលដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ បន្ទាប់ពីយើងប្រើប្រាស់
ឬក៏ដាក់កាតចូលទៅក្នុងម៉ាស៊ីនអេធីអឹមរួចហើយ យើងត្រូវបញ្ចូលលេខសម្ងាត់។
អញ្ចឹងនៅក្នុងរូបភាពទី ២ នេះ គឺយើងវ៉ែ គឺនារីនោះវាយលេខសម្ងាត់បញ្ចូល។
អញ្ចឹងនៅក្នុងប្រទេសកម្ពុជា ម៉ាស៊ីនអេធីអឹម គឺប្រើប្រាស់ភាសាខ្មែរ ហើយនិងភាសាអង់គ្លេស
ឬក៏ភាសាអង់គ្លេស។ អញ្ចឹងប្រសិនបើយើងជាជនជាតិខ្មែរ យើងត្រូវជ្រើសរើសភាសាខ្មែរ
ហើយប្រសិនបើយើងជនជាតិបរទេស ឬក៏មិនចេះប្រើប្រាស់ភាសាខ្មែរនោះទេ
យើងត្រូវប្រើប្រាស់ភាសាអង់គ្លេស ព្រោះថានៅលើម៉ាស៊ីនទាំងអស់ គឺមានពីរភាសា គឺភាសាខ្មែរ
និងភាសាអង់គ្លេស។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះ គាត់ប្រើប្រាស់ភាសាអង់គ្លេស បាទ
ហើយគាត់បញ្ចូលលេខសម្ងាត់។ អញ្ចឹងបន្ទាប់ពីជ្រើសរើសភាសាហើយ
យើងត្រូវបញ្ចូលលេខសម្ងាត់របស់យើងចូលទៅក្នុងទូអេធីអឹម ដើម្បីសម្គាល់ថា
គណនីរបស់អ្នកណា។ អញ្ចឹងនារីម្នាក់នោះ គាត់បានបញ្ចូលលេខសម្ងាត់ចំនួន ៤ ខ្ទង់
ទៅក្នុងម៉ាស៊ីនអេធីអឹមសម្រាប់គណនីធនាគាររបស់គាត់ បាទ ហើយនៅលើទូអេធីអឹមនោះ
គឺមានបង្ហាញអំពីអេក្រង់មួយ បាទ អេក្រង់មួយ
ដើម្បីឲ្យយើងមើលឃើញលំដាប់លំដោយនៃការដកប្រាក់
គឺឲ្យយើងមើលឃើញអំពីការបញ្ចូលលេខសម្ងាត់ ហើយនិងមានប៊ូតុងពីរ បាទ ឬក៏គ្រាប់ចុចចំនួនពីរ
ដែលមានមួយពណ៌ក្រហម និងមួយទៀតពណ៌ខៀវ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងរូបភាពទី ៨ បាទ នៅក្នុងរូបភាពទី ៨ បន្ទាប់ពីនារីម្នាក់នោះ
គាត់បានបញ្ចូលលេខសម្ងាត់រួចរាល់ហើយ យើងឃើញថា យើងត្រូវបញ្ចូលចំនួនទឹកប្រាក់
ដែលយើងត្រូវការដក។ អញ្ចឹងនៅក្នុងរូបភាពទី ៨ នេះ នារីម្នាក់នោះ
គាត់បានវាយបញ្ចូលលេខទឹកប្រាក់ចំនួន ១៥០០ ដុល្លារ អញ្ចឹងគាត់ត្រូវការប្រាក់ចំនួន ១៥០០
ដុល្លារ ហើយនៅលើអេក្រង់ ឬក៏នៅលើស្រ្គីន បាទ យើងហៅថាអេក្រង់ គឺមានបង្ហាញលេខចំនួន
១៥០០ ដុល្លារ តាមតម្រូវការរបស់នារីម្នាក់នោះ ហើយមានអក្សរពីរ គឺអក្សរយល់ព្រម
និងអក្សរមិនយល់ព្រម ដែលអក្សរយល់ព្រម គឺនៅគ្រាប់ចុចពណ៌បៃតង រីឯអក្សរមិនយល់ព្រម
គឺនៅប៊ូតុង ឬក៏គ្រាប់ចុចពណ៌[បៃតង] ពណ៌ក្រហម អញ្ចឹងនៅលើរូបភាពនេះ យើងឃើញថា
មានអក្សរ yes និងអក្សរ cancel អញ្ចឹងអក្សរ yes បានន័យថា យល់ព្រម អក្សរ cancel
បានន័យថា មិនយល់ព្រម។ ដូច្នេះម៉ាស៊ីនអេធីអឹមនឹងបញ្ជាក់យើងម្តងទៀត
ថាតើយើងពិតជាយល់ព្រមដកប្រាក់ចំនួន ១៥០០ ដុល្លារនោះដែរឬទេ។
អញ្ចឹងប្រសិនបើយើងយល់ព្រមដកប្រាក់ ១៥០០ ដុល្លារ យើងគ្រាន់តែចុចលើគ្រាប់ចុច yes
ឬក៏គ្រាប់ចុចយល់ព្រម ដើម្បីដកប្រាក់ ឬក៏បើយើងមិនយល់ព្រមទេ
យើងគ្រាន់តែចុចលើគ្រាប់ចុចពណ៌ក្រហម ដែលមានន័យថា មិនយល់ព្រម។
អញ្ចឹងម៉ាស៊ីនអេធីអឹមទាំងអស់ តែងតែសួរបញ្ជាក់ឡើងវិញ បាទ
សួរបញ្ជាក់ឡើងវិញថាយើងយល់ព្រមដកប្រាក់ចំនួនដែលយើងត្រូវការនោះដែរឬទេ។

ចូលមកដល់រូបភាពទី ៩ រូបភាពទី ៩ យើងឃើញថា នារីម្នាក់នោះ
បានចុចទៅលើគ្រាប់ចុចពណ៌បៃតង អញ្ចឹងការចុចលើគ្រាប់ចុចពណ៌បៃតង
បានន័យថាយើងយល់ព្រមទៅនឹងអ្វី ដែលម៉ាស៊ីនអេធីអឹមបានបង្ហាញ បានន័យថានារីម្នាក់នោះ
គាត់យល់ព្រមដកប្រាក់ចំនួន ១៥០០ ដុល្លារ។ អញ្ចឹងគាត់ក៏បានចុចលើគ្រាប់ចុចពណ៌បៃតង
ដោយមានន័យថាយល់ព្រម ដូច្នេះម៉ាស៊ីននឹងធ្វើការបញ្ចេញនូវប្រាក់ចំនួន ១៥០០ ដុល្លារ
តាមតម្រូវការរបស់គាត់តែម្តង បាទ បន្ទាប់ពីយើងយល់ព្រមហើយ។

អញ្ចឹងនៅក្នុងរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ បន្ទាប់ពីយើងបានចុចលើគ្រាប់ចុចយល់ព្រម
នារីម្នាក់នោះ គាត់ក៏បានរង់ចាំឲ្យម៉ាស៊ីនដំណើរការ។ អញ្ចឹងបន្ទាប់ពីយើងយល់ព្រមហើយ
ម៉ាស៊ីនក៏ចាប់ផ្តើមដំណើរការរបស់វា ដើម្បីបញ្ចេញប្រាក់ចំនួន ១៥០០ ដុល្លារ។
ម៉ាស៊ីនបានធ្វើការរាប់ប្រាក់ទៅក្នុងគណនីរបស់គាត់
ឬក៏ពិនិត្យទៅលើសាច់ប្រាក់នៅក្នុងគណនីរបស់គាត់ តើគណនីរបស់គាត់
មានសាច់ប្រាក់គ្រប់គ្រាន់ចំនួន ១៥០០ ដុល្លារដែរឬទេ ដូច្នេះគឺយើងត្រូវរង់ចាំរយៈពេលមួយសន្ទុះ
បាទ ឬក៏រយៈពេលបន្តិច ឬក៏ភាសាខ្មែរ ឬក៏ប្រជាជនខ្មែរនិយមហៅថា រយៈពេលមួយសន្ទុះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីឲ្យម៉ាស៊ីនត្រួតពិនិត្យសាច់ប្រាក់នៅក្នុងគណនី។ អញ្ចឹងនៅក្នុងរូបភាពនេះ នារីម្នាក់នោះ គាត់ក៏កំពុងតែឈររង់ចាំឲ្យម៉ាស៊ីនត្រួតពិនិត្យទៅលើគណនីរបស់គាត់ផងដែរ។

ចូលដល់រូបភាពទី ១១ រូបភាពទី ១១ បន្ទាប់ពីពិនិត្យគណនីរួចហើយ ម៉ាស៊ីនដកប្រាក់បានបញ្ចេញកាតអេធីអឹមរបស់គាត់ចេញមកក្រៅវិញ មុននឹងបញ្ចេញលុយ។ អញ្ចឹងជាទូទៅគឺគាត់បញ្ចេញកាតអេធីអឹមមកវិញ បាទ នៅពេលដែលគាត់ពិនិត្យហើយ ថាតើមានទឹកប្រាក់គ្រប់គ្រាន់ដែរឬទេ បាទ ទោះជាគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ក៏ដោយ ម៉ាស៊ីនតែងតែបញ្ចេញកាតអេធីអឹមមកវិញ ហើយយើងត្រូវចាប់កាន់[ម៉ាស៊ីន]កាតអេធីអឹមនោះ ដើម្បីយកមកទុក។ អញ្ចឹងនៅក្នុងរូបភាពនេះ កាតអេធីអឹមគឺចេញមកក្រៅតាមរយៈកន្លែងដោតកាត អញ្ចឹងកន្លែងដោតកាតនៅកន្លែងណា ម៉ាស៊ីនអេធីអឹមនឹងបញ្ចេញកាតនៅកន្លែងនោះមកវិញ។ យើងឃើញកាតអេធីអឹមពណ៌ទឹកក្រូចចេញពីរន្ធមួយ បាទ រន្ធមួយ រន្ធនោះគឺជារន្ធដែលបញ្ចេញ ឬក៏បញ្ចូលកាតអេធីអឹម។ អញ្ចឹងរូបភាពនេះ គឺកាតអេធីអឹម គឺចេញមកក្រៅ។

ចូលដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា បន្ទាប់ពីអេធីអឹមនោះបញ្ចេញកាតចេញមកក្រៅហើយ នារីម្នាក់នោះ គាត់ក៏បានយកដៃស្តាំរបស់គាត់ ចាប់[កាន់] ចាប់កាតអេធីអឹមនោះ ដើម្បីកុំឲ្យធ្លាក់ អញ្ចឹងប្រសិនបើយើងអត់ចាប់កាន់កាតអេធីអឹមនោះទេ ម៉ាស៊ីនអេធីអឹមនឹងទាញកាតអេធីអឹមនោះ ចូលទៅក្នុងម៉ាស៊ីនវិញ។ ដូច្នេះនៅពេលដែលម៉ាស៊ីនអេធីអឹមគាត់បញ្ចេញកាតចេញមកភ្លាម យើងត្រូវចាប់កាតនោះ ហើយដកចេញពីម៉ាស៊ីនភ្លាមៗផងដែរ ដើម្បីកុំឲ្យម៉ាស៊ីនអេធីអឹមទាញកាតនោះចូលទៅវិញ ព្រោះដើម្បីរក្សាសុវត្ថិភាពគឺ ម៉ាស៊ីនអេធីអឹម នៅពេលដែលបញ្ចេញកាតហើយគ្មានអ្នកយក ម៉ាស៊ីននោះនឹងទាញកាតចូលត្រលប់ចូលទៅក្នុងម៉ាស៊ីនវិញ។ ដូច្នេះយើងនឹងមិនអាចដកកាតនោះបានមកវិញទៀតទេ។ អញ្ចឹងភ្លាមៗ បន្ទាប់ពីម៉ាស៊ីនបញ្ចេញកាតមក យើងត្រូវដកកាតចេញពីអេធីអឹម ដូចម្នាក់ រូបភាពនារីម្នាក់នេះ គាត់បានដកកាតចេញពីម៉ាស៊ីនអេធីអឹមរបស់គាត់ភ្លាមៗ បន្ទាប់ពីម៉ាស៊ីនអេធីអឹមបញ្ចេញកាត។

ចូលដល់រូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់ពីម៉ាស៊ីនអេធីអឹមបញ្ចេញកាតរួចរាល់ហើយ ម៉ាស៊ីនអេធីអឹមក៏គាត់បានបញ្ចេញទឹកប្រាក់ទៅតាមតម្រូវការរបស់នារីម្នាក់នោះផងដែរ។ អញ្ចឹងបានន័យថា នៅក្នុងគណនីធនាគាររបស់នារីម្នាក់នោះ មានទឹកប្រាក់គ្រប់គ្រាន់ សម្រាប់ការដកចំនួន ១៥០០ ដុល្លារ។ ដូច្នេះហើយម៉ាស៊ីនអេធីអឹមក៏បានបញ្ចេញសាច់ប្រាក់ចំនួន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

១៥០០ ដុល្លារ ចេញពីក្នុងម៉ាស៊ីនមកផងដែរ។ អញ្ចឹងការបញ្ចេញសាច់ប្រាក់ និងបញ្ចេញកាត គឺមានកន្លែងខុសគ្នា គឺកន្លែងបញ្ចេញកាតគឺមានតូច បានន័យថារន្ធមួយតូច ដើម្បីបញ្ចេញកាតអេធីអឹម ក៏ប៉ុន្តែកន្លែងបញ្ចេញសាច់ប្រាក់ គឺមានរន្ធធំ អញ្ចឹងទៅតាមទំហំសាច់ប្រាក់។ ដូច្នេះទឹកប្រាក់ចំនួន ១៥០០ ដុល្លារ គឺកំពុងតែត្រូវបានបញ្ចេញពីក្នុងម៉ាស៊ីនអេធីអឹម។ ជាទូទៅការបញ្ចេញសាច់ប្រាក់ គឺគេមិនបញ្ចេញប្រាក់ទាំងមូលមកនោះទេ គឺគេបញ្ចេញតែពាក់កណ្ដាលតែប៉ុណ្ណោះ ដូច្នេះយើងត្រូវចាប់ទាញសាច់ប្រាក់នោះចេញពីម៉ាស៊ីនផងដែរ។

ចូលដល់ក្នុងរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីម៉ាស៊ីនអេធីអឹមនោះ បានបញ្ចេញសាច់ប្រាក់តាមរន្ធសាច់ប្រាក់ចេញមកក្រៅហើយ នារីម្នាក់នោះ គាត់បានយកដៃស្ដាំរបស់គាត់ចាប់ទាញសាច់ប្រាក់ចេញមក អញ្ចឹងម៉ាស៊ីនអេធីអឹម គាត់បានបញ្ចេញតែពាក់កណ្ដាលនៃទំហំសាច់ប្រាក់នោះទេ ដូច្នេះហើយ យើងត្រូវចាប់ទាញចេញមកក្រៅ ដើម្បីយកលុយទាំងនោះ ព្រោះថាប្រសិនបើម៉ាស៊ីនបញ្ចេញលុយទាំងមូល លុយនឹងអាចធ្លាក់ បាទ លុយនឹងអាចធ្លាក់ចុះ ហើយរាយប៉ាយ ដូច្នេះហើយ ដើម្បីរក្សាសណ្ដាប់ធ្នាប់នោះ ម៉ាស៊ីនគឺបញ្ចេញលុយតែពាក់កណ្ដាលខ្លួន ឬក៏ពាក់កណ្ដាលនៃសាច់ប្រាក់នោះតែប៉ុណ្ណោះ ដើម្បីឲ្យម្ចាស់សាច់ប្រាក់ ឬក៏ឲ្យនារីនោះ ចាប់ទាញចេញមក ដូច្នេះលុយទាំងនោះ គឺមិនធ្លាក់រាយប៉ាយគ្មានសណ្ដាប់ធ្នាប់នោះទេ គឺលុយនឹងរក្សាបានសណ្ដាប់ធ្នាប់របស់វាល្អតែម្ដង។

នៅក្នុងរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥
បន្ទាប់ពីយើងចាប់ទាញលុយចេញពីម៉ាស៊ីនអេធីអឹមហើយ យើងត្រូវរាប់លុយមើលនោះ ឲ្យបាន លុយនោះ មើលឲ្យបានច្បាស់ គឺយើងត្រូវពិនិត្យសាច់ប្រាក់ ហើយរាប់នូវចំនួន ថាតើម៉ាស៊ីនអេធីអឹមរបស់យើងបញ្ចេញលុយគ្រប់ចំនួនដែលយើងត្រូវការដែរឬទេ ឬក៏បញ្ចេញលុយគ្រប់ចំនួននូវអ្វីដែលយើងដកនោះដែរឬទេ ប្រសិនបើមិនគ្រប់ចំនួនទេ គឺយើងត្រូវប្ដឹង ឬក៏យើងត្រូវទៅនិយាយប្រាប់ទៅដល់បុគ្គលិករបស់ធនាគារ ថាម៉ាស៊ីនអេធីអឹមបញ្ចេញលុយមិនបានគ្រប់ចំនួននោះទេ ដូច្នេះប្រសិនបើម៉ាស៊ីនអេធីអឹមបញ្ចេញលុយគ្រប់ចំនួន យើងត្រូវរាប់ឲ្យបានច្បាស់ មុននឹងដាក់ចូលទៅក្នុងកាបូប។ នៅក្នុងរូបភាពទី ១៥ នេះ នារីម្នាក់នោះ គាត់បានពិនិត្យសាច់ប្រាក់ និងពិនិត្យចំនួនទឹកប្រាក់របស់គាត់ថាគ្រប់ចំនួនរួចហើយ ដូច្នេះក្រៅពីពិនិត្យសាច់ទឹកប្រាក់ថាគ្រប់ចំនួនហើយឬនៅ យើងត្រូវពិនិត្យទឹកប្រាក់នោះផងដែរ ថាតើលុយនោះជាលុយត្រឹមត្រូវពិតប្រាកដ ឬក៏លុយក្លែងក្លាយ ប្រសិនបើយើងដកចំលុយក្លែងក្លាយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវប្តឹងទៅធនាគារនោះភ្លាមៗ បន្ទាប់ពីយើងដកប្រាក់ ដើម្បីបញ្ជាក់ថា លុយនោះ គឺជាលុយក្លែងក្លាយ ក៏ប៉ុន្តែប្រសិនបើលុយនោះជាលុយពិតប្រាកដ យើងត្រូវរាប់ឲ្យបានច្បាស់លាស់ថាតើលុយនោះគ្រប់ចំនួនដែលយើងត្រូវការដែរឬទេ បាទ ប្រសិនបើគ្រប់ចំនួនតម្រូវការហើយ យើងអាចយកមកទុកបាន ហើយធ្វើដំណើរទៅវិញ ប៉ុន្តែប្រសិនបើមិនគ្រប់ទេ យើងត្រូវទៅប្តឹងធនាគារម្តងទៀតដូចគ្នា។ នៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះ គាត់បានពិនិត្យសាច់ប្រាក់រួចរាល់ហើយ ហើយសាច់ប្រាក់របស់គាត់គឺគ្រប់ចំនួន ហើយនិងត្រឹមត្រូវទៅតាមអ្វីដែលគាត់ត្រូវការ ដូច្នេះគាត់ក៏បានយកសាច់ប្រាក់នោះ ដាក់ទៅក្នុងកាបូបលុយពណ៌ទឹកក្រូចរបស់គាត់។ អញ្ចឹងគាត់ក៏បានយកលុយនោះ ដាក់ចូលទៅក្នុងកាបូបលុយពណ៌ទឹកក្រូចរបស់គាត់ តាមតម្រូវការរបស់គាត់។

ចូលដល់រូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីនារីនោះ គាត់ប្រើប្រាស់ម៉ាស៊ីនអេធីអឹម ដើម្បីដកប្រាក់រួចរាល់ហើយ គាត់ក៏បានដើរចេញពីម៉ាស៊ីននោះ បានន័យថាគាត់យកលុយនិងកាតអេធីអឹមរក្សាទុកនៅក្នុងកាបូបគាត់រួចរាល់ហើយ គាត់ក៏បានដើរចេញ បានន័យថាគាត់ក៏លែងត្រូវការប្រើប្រាស់ម៉ាស៊ីនអេធីអឹមនោះរួចទៀតហើយ អញ្ចឹងគាត់ដើរចេញ ដើម្បីឲ្យអ្នកដទៃប្រើប្រាស់ម្តង។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា បន្ទាប់ពីគាត់ដើរចេញ គឺមាននារីម្នាក់ទៀតពាក់អាវសដៃខ្លីខោជើងវែងពណ៌ខ្មៅ ក៏បានចូលទៅប្រើប្រាស់ម៉ាស៊ីនអេធីអឹមនោះម្តង។ បានន័យថាអម្បាញ់មិញ នារីនោះ គាត់ឈរពីក្រោយនារីពាក់អាវខៀវ ដើម្បីរង់ចាំ។ អញ្ចឹងការប្រើប្រាស់ម៉ាស៊ីនមួយ ដែលមានគ្នាច្រើនសម្រាប់ប្រើប្រាស់ យើងត្រូវតម្រង់ជួរគ្នា ដើម្បីរក្សាសណ្តាប់ធ្នាប់។ ដូចនៅក្នុងរូបភាពនេះអញ្ចឹង គឺគេប្រើប្រាស់ម្តងម្នាក់ៗ។ បន្ទាប់ពីនារីដែលពាក់អាវខៀវ ឬក៏ពាក់អាវពណ៌ទឹកសមុទ្រនោះ ដើរចេញពីម៉ាស៊ីន បានន័យថាគាត់ប្រើប្រាស់ម៉ាស៊ីននោះរួចរាល់ហើយ មាននារីម្នាក់ទៀត គាត់ចូលប្រើប្រាស់ម្តង។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺបង្ហាញអំពីការប្រើប្រាស់អេធីអឹមរួចរាល់ហើយ ហើយដើរចេញពីម៉ាស៊ីនអេធីអឹម ដើម្បីឲ្យអ្នកដទៃចូលប្រើប្រាស់ម៉ាស៊ីនអេធីអឹម ដើម្បីដកប្រាក់របស់គេម្តងវិញ។ អញ្ចឹងយើងត្រូវការប្រើប្រាស់ម្តងម្នាក់ៗ ដោយរក្សានូវសណ្តាប់ធ្នាប់និងសុជីវធម៌របស់យើង ឲ្យបានខ្ពស់បំផុតនៅក្នុងការប្រើប្រាស់របស់រួម។ ម៉ាស៊ីនអេធីអឹមគឺជារបស់រួម ដូច្នេះយើងត្រូវប្រើប្រាស់ដោយមានសុជីវធម៌ជាទីបំផុត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.